ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៣.បប

# បទបញ្ជា
## ស្តីពី
## ការរក្សាការពារ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ នៅតាមតំបន់រោងចក្រ សហគ្រាស និងតំបន់ឧស្សាហកម្ម

រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ការអភិវឌ្ឍសេដ្ឋកិច្ចជាតិមានការរីកចម្រើនយ៉ាងឆាប់រហ័ស ក្នុងនោះវិស័យកម្មន្តសាលមានការអភិវឌ្ឍយ៉ាងលឿន ហើយមានគ្រឹះស្ថានផលិតកម្ម សេវាកម្មជាច្រើនត្រូវបានបង្កើតឡើង ផ្តល់ការងារធ្វើរាប់លានដល់ប្រជាពលរដ្ឋ។ ទន្ទឹមនឹងការអភិវឌ្ឍសេដ្ឋកិច្ច ការអនុវត្តសិទ្ធិសេរីភាពក្នុងការបង្កើតសហជីព អង្គការ វិជ្ជាជីវៈ សិទ្ធិកូដកម្ម បាតុកម្ម ត្រូវបានធានាដោយច្បាប់ និងបានអនុវត្តយ៉ាងទូលំទូលាយ។ ប៉ុន្តែថ្មីៗនេះ មានកូដកម្ម បាតុកម្មនៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន បានកើតឡើងជាបន្តបន្ទាប់ ក្នុងនោះមានករណីខ្លះញុះញង់បង្កភាពអនាធិបតេយ្យ បង្កើតអំពើហិង្សា បំផ្លាញទ្រព្យសម្បត្តិសាធារណៈ ទ្រព្យសម្បត្តិឯកជន និងធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។ ទន្ទឹមនេះ កម្មករនិយោជិតយើង ក៏ត្រូវបានក្រុមជនមួយចំនួនបង្ខិតបង្ខំធ្វើការអូសទាញ បោកបញ្ឆោត ញុះញង់ឱ្យចូលរួមធ្វើកូដកម្ម បាតុកម្ម។ និយោជកនៃគ្រឹះស្ថានមួយចំនួនអនុវត្តមិនបានគ្រប់គ្រាន់តាមច្បាប់ជាធរមាន ធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់កម្មករនិយោជិត ហើយមិនព្រមសហការដោះស្រាយបញ្ហាឱ្យបានឆាប់រហ័ស ដែលជាហេតុនាំឱ្យកើតមានកូដកម្ម បាតុកម្ម។ បាតុភាពនេះធ្វើឱ្យសាធារណជនមានការព្រួយបារម្ភ ធ្វើឱ្យប៉ះពាល់ដល់បរិយាកាសវិនិយោគ ធ្វើឱ្យប៉ះពាល់ដល់ជីវភាពរបស់កម្មករនិយោជិត និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។

ដើម្បីអន្តរាគមន៍ បង្ការ ទប់ស្កាត់ ដោះស្រាយ និងតម្រង់ទិសការអនុវត្តសិទ្ធិធ្វើកូដកម្ម ឱ្យស្របតាមច្បាប់ស្តីពីការងារ និងការអនុវត្តសិទ្ធិធ្វើបាតុកម្ម ឱ្យស្របតាមច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវបទបញ្ជាដូចខាងក្រោម៖

១-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថ/

លើផ្ទៃប្រទេស គណៈបញ្ជាការឯកភាពរាជធានី-ខេត្ត និងក្រសួងពាក់ព័ន្ធនានា ត្រូវដាក់បទបញ្ជាយ៉ាងម៉ឺងម៉ាត់បំផុតដល់មន្ត្រីក្រោមឱវាទរបស់ខ្លួន ឱ្យពង្រឹងការអនុវត្តច្បាប់ស្ដីពីការងារ ច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី។ យកចិត្តទុកដាក់ណែនាំ និងពង្រឹងការអនុវត្តច្បាប់ចំពោះនិយោជក អង្គការសហជីព និងកម្មករនិយោជិត ខិតខំដោះស្រាយរាល់វិវាទការងារតាមនីតិវិធីច្បាប់តាំងពីពេលចាប់ផ្ដើមដំបូង ចៀសវាងការអូសបន្លាយពេលវេលាដែលនាំបញ្ហារាលដាលទៅជាធំ។

ក្នុងករណីដែលភាគីណាគ្មានឆន្ទៈដោះស្រាយ ឬមិនគោរពតាមនីតិវិធីកូដកម្មនៅក្នុងច្បាប់ស្ដីពីការងារ និងនីតិវិធីនៃច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវចាត់វិធានការឱ្យបានម៉ឺងម៉ាត់ រក្សាការពារសន្តិសុខសណ្ដាប់ធ្នាប់ និងចាត់វិធានការតាមច្បាប់។

២-និយោជកតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន ត្រូវគោរព និងអនុវត្តច្បាប់ លិខិតបទដ្ឋានជាធរមាន ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានល្អនូវលក្ខខណ្ឌការងារ សុវត្ថិភាព អនាម័យ សន្តិសុខការងារ គោរពសិទ្ធិស្របច្បាប់របស់សហជីព មិនរើសអើងចំពោះសហជីព និងត្រូវសហការឱ្យបានល្អជាមួយសហជីពដែលមានភាពជាតំណាងបំផុត ក្នុងការធ្វើអនុសញ្ញារួម ដើម្បីសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈនៃរោងចក្រ សហគ្រាស គ្រឹះស្ថាន។

ក្នុងករណីមានវិវាទកើតឡើង ត្រូវផ្ដល់ព័ត៌មានជាបន្ទាន់ទៅស្ថាប័នមានសមត្ថកិច្ច និងត្រូវចាត់តំណាងដែលមានសិទ្ធិសម្រេចចូលរួមក្នុងការចរចា និងដោះស្រាយដោយសន្តិវិធី។ ព្រមជាមួយនោះត្រូវអនុវត្តឱ្យបានត្រឹមត្រូវនូវនីតិវិធីឡុកអៅ។

៣-អង្គការសហជីពត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមអនុសញ្ញាលេខ៨៧ និង៩៨ របស់អង្គការពលកម្មអន្តរជាតិខាងការងារស្ដីពីសេរីភាពសហជីព និងការចរចាអនុសញ្ញារួម និងត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ស្ដីពីការងារ បទប្បញ្ញត្តិធរមាន និងលក្ខន្តិកៈរបស់អង្គការសហជីពផ្ទាល់។ សហជីពដែលមានសម្លេងភាគតិច ត្រូវសហការជាមួយសហជីពដែលមានភាពជាតំណាងបំផុត។

ពេលមានវិវាទការងារកើតឡើង ត្រូវព្យាយាមរកដំណោះស្រាយឱ្យអស់លទ្ធភាព ដោយឈរលើស្មារតីច្បាប់ជាធរមាន ក្នុងការសហការសម្របសម្រួលដើម្បីផលប្រយោជន៍រួម និងត្រូវអនុវត្តតាមនីតិវិធី និងយន្តការដែលមានជាធរមាន ដូចជា អធិការការងារ គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្មបាតុកម្មនៅតាមគ្រប់មុខសញ្ញា ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ចុងក្រោយបើភាគីណាមិនសុខចិត្ត ត្រូវប្ដឹងទៅតុលាការ គប្បីខិតខំចៀសវាងជាអតិបរមានូវការធ្វើកូដកម្ម បាតុកម្ម។

អង្គការសហជីពនានា ត្រូវគោរពគ្នាទៅវិញទៅមក មិនគប្បីប្រកួតប្រជែងដណ្ដើមប្រជាប្រិយភាពដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ត្រូវត្រួតពិនិត្យអ្នកដឹកនាំ និងសមាជិករបស់ខ្លួនឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ និងលក្ខន្តិកៈរបស់ខ្លួន។

៤-បងប្អូនកម្មករកម្មការិនីត្រូវចូលរួមក្នុងការគោរពនិងអនុវត្តច្បាប់ ចូលរួមក្នុងការរក្សាភាពសុខសាន្ត សាមគ្គីភាពនៅក្នុងកន្លែងធ្វើការ អនុវត្តបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ សហគ្រាស គ្រឹះស្ថាន ចាត់ទុករោងចក្រ សហគ្រាស គ្រឹះស្ថាន ជាឆ្នាំងបាយរួមរបស់កម្មករនិយោជិត និងនិយោជក។ ៗ៳

៥-គណៈអភិបាលរាជធានី-ខេត្ត ត្រូវរៀបចំបង្កើត និងពង្រឹងគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា នៅថ្នាក់រាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក ឃុំ សង្កាត់ ដើម្បីចាត់វិធានការទប់ស្កាត់ និងអន្តរាគមន៍ដោះស្រាយឱ្យបានទាន់ពេលវេលារាល់ករណីកូដកម្ម បាតុកម្ម។

៦-កងកម្លាំងនគរបាលជាតិ កងរាជអាវុធហត្ថ និងកម្លាំងមានសមត្ថកិច្ច ត្រូវចាត់វិធានការឱ្យបានម៉ឺងម៉ាត់បំផុតក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ ប្រឹងប្រែងឱ្យអស់ពីលទ្ធភាព រាំងខ្ទប់រាល់អំពើហិង្សា ការបិទផ្លូវសាធារណៈ ការគប់ឬវាយបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ទ្រព្យសម្បត្តិឯកជន ការរារាំងមធ្យោបាយដឹកជញ្ជូនទំនិញរបស់រដ្ឋឬឯកជន ការចាក់សោបង្ខាំងមនុស្ស ការបង្ករបួសស្នាម ការគំរាមកំហែងកម្មករមិនឱ្យចូលធ្វើការ។ល។និង។ល។

ត្រូវខិតខំការពារសន្តិសុខសុវត្ថិភាពជូនអង្គការសហជីព បងប្អូនកម្មករនិយោជិត ដែលធ្វើកូដកម្ម បាតុកម្មស្របច្បាប់។

ក្នុងករណីមានអំពើហិង្សា ត្រូវចាត់វិធានការតាមនីតិវិធី កសាងសំណុំរឿងបញ្ជូនទៅតុលាការ។

៧-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា ត្រូវដឹកនាំសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ក្នុងការអនុវត្តបទបញ្ជានេះឱ្យបានម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់។

គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តបទបញ្ជានេះ ឱ្យបានម៉ឺងម៉ាត់បំផុត និងមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។៚

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ មីនា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ